ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៦២

ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣

សាលដីកា

លេខ : ៣៥

ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤

# គាមនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គឹមសាន ចៅក្រម

៤- លោក ស៊ិន ឌីម ចៅក្រម

៥- លោក ប៉ែន សារឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក ឈាង វន្ឋា

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក ពីសាលដីកាព្រហ្មទណ្ឌលេខ១០១"ង" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦២ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣របស់តុលាការកំពូល ។

<u>ពីបទ</u> : អំពើប្លន់ និង កាន់អាវុធ ឬ ដឹកជញ្ជូនអាវុធដែលហាមឃាត់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា៣៤-៩៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះជន ជាន់ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឈើទាល ឃុំថ្កោជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ឪពុកឈ្មោះឡុច ជន "រ" ម្តាយឈ្មោះមាន ជួន "ស" ។ នៅលីវ ។ ទោសពីមុនគ្មាន ។

-មេធាវីលោក ជ សម្បត្តិ

២-ជនជាប់ចោទឈ្មោះយស់ សាឡាត់ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាកែល ឃុំប៊ុនជ័យ ស្រុករំដួល ខេត្តស្វាយរៀង ទីលំនៅភូមិបារ៉ាប សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុង

ភ្នំពេញ ឪពុកឈ្មោះយស់ នោម "ស្លាប់" ម្ដាយឈ្មោះព្រំ ទ្រុម "រស់" ប្រពន្ធឈ្មោះចាន់ សារ៉េត មានកូន២នាក់ ទោសពីមុនគ្មាន ។

-មេធាវី : លោកលួង សុខា

៣-ជនជាប់ចោទឈ្មោះកុន សុភ័ក្រ "ចុងបណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃស្លួល ឃុំគោកខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានទីលំនៅមិនពិតប្រាកដ ឪពុកឈ្មោះដឹង ក្រិត "ស្លាប់" ម្ដាយឈ្មោះភិន ខាន់ "រស់" ប្រពន្ធឈ្មោះជ័យ ហួយ កូនគ្មាន ទោសពីមុនគ្មាន ។

-មេធាវី : លោក ជ សម្បត្តិ

៤-ជនជាប់ចោទឈ្មោះជ័យ ហួយ "ចុងបណ្ដឹងសាទុក្ខ" ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ កើតនិងទីលំនៅសព្វថ្ងៃមណ្ឌល សង្កាត់បិតត្រាំង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ឪពុកឈ្មោះជ័យ យ៉ាន "រស់" ម្ដាយឈ្មោះណាវ ពួយ "រស់" ប្ដីឈ្មោះកុន សុភ័ក្រ មានកូន០១នាក់ ។

-មេធាវី : លោក ជ សម្បត្តិ

៥-ជនជាប់ចោទឈ្មោះឡាច ម៉ាប់ ហៅ ជន ជល "ចុងបណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ២៥ឆ្នាំ កើតនៅភូមិឈើទាល ឃុំថ្កៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មុខរបរកងរាជអាវុធហត្ថលើផ្ទៃប្រទេសប្រចាំខេត្តសៀមរាប ឪពុកឈ្មោះឡុត ជន "រស់" ម្ដាយឈ្មោះមាន ជួន "ស្លាប់" ប្រពន្ធឈ្មោះពៅ មាន ទោសពីមុនគ្មាន។ គេចខ្លួន ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសៅ វុទ្ធី និង អ្នកស្រីទុន ទាង "ម្ចាស់បណ្ដឹងសាទុក្ខ" មានទីលំនៅក្រុម១៣ មណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

តាមរបាយការណ៍លេខ១៨៤ របក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ របស់ការិយាល័យនគរបាលយុត្តិធម៌ក្រុងព្រះសីហនុបញ្ជាក់ថា នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០០ ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និង អធិការនគរបាលខ័ណ្ឌមិត្តភាពចុះអនុវត្តដីកាខេត្តកំពង់ចាម និង ក្រុងភ្នំពេញ ចាប់បានជនល្មើស៤នាក់គឺ :

១-ឈ្មោះជន ជាន់ ដកហូតបានម៉ូតូC100កូរ៉េ២គ្រឿង ខ្សែកច្រវ៉ាក់រនាប០១ខ្សែទំងន់៧ជីមាស និង បន្តោងរូបព្រះ១ ចិញ្ចៀនមាស០១វង់ ទំងន់២ជី នាឡិកាដៃ១គ្រឿងប្រទេសហ្គូលស្ដាពណ៌ក្រហម។

២-ឈ្មោះទុក សុភ័ក្រ្ត ដកហូតបានប្រាក់ដុល្លា ចំនួន៣០០$ ខ្សែកមាស០១ខ្សែ ផ្កាស្លាប្រវែង០៦តឹក ២បណ្ដោងរូបផ្កាយ០១ដាំត្បូងចំនួន១៨គ្រាប់ ទំពូកខ្សែមាស០១ខ្សែ ដៃប្លាទីន០១ ។

៣-ឈ្មោះយស់ សាឡាត់ ដកហូតបានរថយន្តតូយ៉ូណា១គ្រឿងពណ៌ស សេរី៨៤ ខ្សែកមាសប្រវែង៧តឹក០១ខ្សែ ខ្សែកប្លាទីន៥តឹកចំនួន០១ខ្សែ ខ្សែចង្កេះប្លាទីន២ខ្សែ មាសដុំចំនួន៣ដុំ បណ្ដោងប្លាទីនរូបសត្វចំនួន១០បណ្ដោង រូបព្រះ និង បណ្ដោងត្បូងចំរុះពណ៌មានតូចធំ២០ ចិញ្ចៀនត្បូងប្លាទីនដាំត្បូងចំនួន២វង់ ក្រវិលប្លាទីនចំនួន០១ ខ្សែដៃប្លាទីនកូនក្មេង០១ខ្សែ ។

៤-ឈ្មោះជ័យ ហួយ ជាប្រពន្ធរបស់ឈ្មោះកុន សុភ័ក្រ្ត ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងព្រះសីហនុ ថា :

១-ចោទប្រកាន់លើឈ្មោះ :

ក/-ផន ផល ហៅឡាច ម៉ាប់ អាយុ២៥ឆ្នាំ កើតនៅភូមិឈើទាល ឃុំផ្ដៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មុខរបរធ្វើការនៅខេត្តសៀមរាប ឪពុកឈ្មោះឡុច ផន "រ" ម្ដាយឈ្មោះមាន ជួន "ស" ប្រពន្ធឈ្មោះពៅ ។

ខ/-ផន ផាន់ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឈើទាល ឃុំផ្ដៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ធ្វើស្រែ ឪពុកឈ្មោះឡុច ផន "រ" ម្ដាយឈ្មោះមាន ជួន "ស" ទោសពីមុខគ្មាន ។

គ/-ទុន សុភ័ក្រ្ត ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃស្នួល ឃុំគោកខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្រពន្ធឈ្មោះជ័យហួយ ឪពុកឈ្មោះជឹង គ្រិត "ស" ម្ដាយឈ្មោះកិក ខាន់ "រ" ។

ឃ/-យស់ សាឡាត់ ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាកែល ឃុំម៉ឺនជ័យ ស្រុករំដួល ខេត្តស្វាយរៀង មុនចាប់ខ្លួននៅភូមិបាយ៉ាប ឃុំភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះយស់ នោម ម្ដាយឈ្មោះព្រំ ទ្រុប "ស" ប្រពន្ធឈ្មោះចាន់ សារ៉េត មានកូន២នាក់ ។

ង/-ជ័យ ហួយ ភេទស្រី អាយុ២៧ឆ្នាំ កើតនៅភូមិបិតត្រាំង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តកំពត សព្វថ្ងៃនៅក្រុម៤ មណ្ឌលបិតត្រាំង សង្កាត់បិតត្រាំង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របរធ្វើស្រែ ប្ដីឈ្មោះទុន សុភ័ក្រ្ត មានកូន០១នាក់ ឪពុកឈ្មោះជ័យ យ៉ាន "រ" ម្ដាយឈ្មោះណាវ ពួយ "រ" ។

ពីបទ : ប្លន់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

២-ចោទប្រកាន់លើឈ្មោះផន ផល ហៅឡាច ម៉ាប់ ,ភុន សុភ័ក្រ្ត ,ផន ផល ពីបទប្រើប្រាស់អាវុធដែលហាមឃាត់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គង់បណ្ដឹងអាជ្ញាឈ្មោះពៅ ភេទស្រី ពីបទប្លន់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥-១២-២០០០ ដោយជនល្មើសបានគេចខ្លួនបាត់ ។ គ្មានសាវតាជាតិ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងព្រះសីហនុ ដែលបានសំរេច :

១-កែប្រែបទចោទប្រកាន់លើឈ្មោះជ័យ ហួយ ពីបទអំពើប្លន់មកបទទទួលផលតាមអំពើចោរកម្មវិញ ផ្អែកតាមបញ្ញត្តិមាត្រា១០៥ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

២-ផ្ដន្ទាទោស :

ក/-ឈ្មោះឡាច ម៉ាប់ ហៅផន ផល ដាក់ពន្ធនាគារកំបាំងមុខ១០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។ នៅពេលសាលក្រមនេះស្ថាពរត្រូវចាប់ខ្លួនឈ្មោះឡាច ម៉ាប់ ហៅផន ផល យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ។

ខ/-ឈ្មោះភុន សុភ័ក្រ្ត ដាក់ពន្ធនាគារកំណត់០៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។ ពីបទអំពើប្លន់ និង បទការកាន់អាវុធ ឬ ដឹងជញ្ជូនអាវុធដែលហាមឃាត់ ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ បទល្មើសនេះមានចែងអោយផ្តន្ទាទោសតាមមាត្រា៣៤ និង មាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

គ/-ឈ្មោះផន ផល ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

ឃ/-ឈ្មោះយស់ សាឡាត់ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន និង ព្យួរទោស កំណត់០៣ឆ្នាំ សាកល្បង០៥ឆ្នាំ គិតពីពេលអនុវត្តទោសពន្ធនាគាររួច ។

ពីបទ : អំពើប្លន់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃ ទី១៥ ខែធ្នូ ឆ្នាំ២០០០ បទល្មើសដែលផ្តន្ទាទោសតាមមាត្រា៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ង/-ឈ្មោះជ័យ ហួយ ដាក់ពន្ធនាគារ កំណត់០៥ខែ១០ថ្ងៃ គិតពីថ្ងៃចាប់ខ្លួន និង ព្យួរទោស ០១ឆ្នាំ សាកល្បង០៥ឆ្នាំ គិតពីពេលអនុវត្តទោសពន្ធនាគាររួច ពីបទទទួលផលតាមអំពើចោរកម្ម ប្រព្រឹត្តនៅ ភ្នំពេញ កាលពីថ្ងៃទី១៦ខែធ្នូឆ្នាំ២០០០ បទល្មើសដែលមានចែងផ្តន្ទាទោសតាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

៣-អោយឈ្មោះឡាច ម៉ាប់ ហៅផន ផល ឈ្មោះភុន សុភ័ក្រ្ត ,ផន ផាន់ រួមគ្នាសងសំណង និង ជំងឺចិត្តជាមាសដល់ជនរងគ្រោះឈ្មោះសៅ វុទ្ធី និង អ្នកស្រីទុន ទៀង ចំនួន៧០តំលឹង ដោយឱ្យឈ្មោះឡាច ម៉ាប់ ហៅផន ផល សងចំនួន៣០តំលឹងមាស ឯឈ្មោះភុន សុភ័ក្រ្ត និង ឈ្មោះផន ផាន់ ក្នុងម្នាក់២០តំលឹងមាស សុំ លើសពីនេះត្រូវលើកចោល ។ ក្នុងករណីទណ្ឌិតទាំង៣នាក់ ពុំមានប្រាក់សងទេ ត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារសំណងធនទណ្ឌតាមបញ្ញត្តិមានមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកដើម្បីទារសំណងធនទណ្ឌក្នុងរឿង ព្រហ្មទណ្ឌ ។

៤-រឹបអូសវត្ថុតាងមាននៅក្នុងកំណត់ហេតុ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ ប្រគល់ឱ្យលោកសៅ វុទ្ធី និង អ្នកស្រីទុន ទៀង គ្រប់គ្រងជាកម្មសិទ្ធិវិញ គិតចាប់ពីពេលសាលក្រមស្ថាពរតទៅ ។

៥-រឹបអូសម៉ូតូC100 កូរ៉េ២គ្រឿង ដែលជាផលនៃអំពើល្មើសប្រគល់ឱ្យទៅលោកសៅ វុទ្ធី និង អ្នកស្រីទុន ទៀង គ្រប់គ្រងជាកម្មសិទ្ធិ ចាប់ពីពេលសាលក្រមស្ថាពរតទៅ ។

៦-រឹបអូសម៉ូតូC100 កូរ៉េមួយគ្រឿង និង រថយន្តម៉ាកតូយ៉ូតាកូរ៉ូណាពណ៌ស មួយគ្រឿង ដែលជាមធ្យោបាយប្រព្រឹត្តបទល្មើសទុកជាសម្បត្តិរដ្ឋចាប់តាំងពីពេលសាលក្រមស្ថាពរតទៅ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ភុន សុភ័ក្រ្ត ,ផន ផាន់ យស់ សាឡាត់ ,ជ័យ ហួយ កំបាំងមុខឈ្មោះឡាច ម៉ាប់ ហៅផន ផល និងចំពោះមុខជនរងគ្រោះ ទុកសិទ្ធិឱ្យ ប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១របស់អ្នកស្រីទុន ទៀង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ៣៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងព្រះសីហនុ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ៣៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០១ ទុកជាបានការតទៅ ដោយគ្រាន់តែបដិសេធចោលចំណុចព្យួរទោស ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០១"ង" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៣៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការប៉ុន្តែលើកលែងចំណុចទី១+២"ឃ" "ង" ចំណុចទី៣ ,៥ និង ទី៦ ត្រូវបដិសេធចោល និង សំរេចជាថ្មី ។

៣-ផ្តន្ទាទោសឈ្មោះយស់ សាឡាត់ និង ជ័យ ហួយ ដាក់ពន្ធនាគារ ក្នុងម្នាក់១២ឆ្នាំ៦ខែ គិតពីថ្ងៃចាប់ខ្លួនពីបទប្លន់ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ ។ មាត្រា៣៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

៤-រឹបអូសម៉ូតូC100 កូរ៉េពារគ្រឿង និង រថយន្តម៉ាកតូយ៉ូតាក្លូរ៉ូណាពណ៌សមួយគ្រឿង ដែលជាមធ្យោបាយប្រព្រឹត្តបទល្មើស លក់ឡាយឡុងដើម្បីយកប្រាក់សងទៅដើមបណ្តឹងរដ្ឋប្បវេណី ។

៥-បង្គាប់អោយជនជាប់ចោទឈ្មោះឡាច ម៉ាប់ ,ភុន សុភ័ក្រ្ត ,ផន ផាន់ ,យស់ សាឡាត់ និង ជ័យ ហួយ រួមគ្នាសងសំណងរដ្ឋប្បវេណីទៅអោយដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៧០តម្លឹងមាស ដោយដកសំណងរដ្ឋប្បវេណី ដែលបានសំរេចក្នុងចំណុចទី៤ នៃសាលដីកានេះ ។

៦-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះទុន ទៀង មេធាវីការពារ ជនជាប់ចោទយស់ សាឡាត់ មេធាវីលោកឡៅ សំអ៊ន់ កំបាំងមុខជនជាប់ចោទទាំងអស់ និង លោកមេធាវី ហេង សុផល ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់អ្នកស្រីទុន ទៀង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១០១"ង" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាចុះថ្ងៃទី១៨-១២-២០០៣ របស់ឈ្មោះទុន ទៀន "ម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងត្រឹមត្រូវតាមគតិច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២៤-១២-២០០៣ របស់ឈ្មោះយស់ សាឡាត់ ធ្វើឡើងត្រឹមត្រូវតាមគតិច្បាប់ ។

-បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

+មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះជន ផល ហៅឡាត ម៉ាប់ .ជន ផាន់ .ភុន សុភ័ក្រ . យស់ សាឡាត់ .ជ័យ ហួយ ពីបទ : អំពើប្លន់ និង កាន់អាវុធ ឬ ដឹងជញ្ជូនអាវុធដែលហាមឃាត់ ប្រព្រឹត្តនៅមណ្ឌល៣ សង្កាត់៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ ។

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១០១"ង"ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះទុន ទាង នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ដោយមូលហេតុថា ចោរប្លន់ខ្លួនមានឈ្មោះជ័យ ហួយ ជាប់គុកបានតែប៉ុន្មានខែទេ គឺចេញមកវិញ ហើយតុលាការបានសំរេចឱ្យជនជាប់ចោទសងខ្លួនបានតែ៧០តំឡឹងមាស ចំណែកឯឡាន .ម៉ូតូ តុលាការសំរេចជាសម្បត្តិរដ្ឋទៀត ។ សូមអោយតុលាការកំពូលជួយដោះស្រាយបញ្ហាទ្រព្យសម្បត្តិ និង ផ្តន្ទាទោសទៅតាមច្បាប់ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះសៅ វុទ្ធី នាពេលសវនាការថា :ខ្លួនមិនយល់សំណងរដ្ឋប្បវេណីនោះទេ ព្រោះថា ការដែលតុលាការសំរេចឱ្យជនជាប់ចោទរួមគ្នាសងមកអោយខ្លួនចំនួន៧០តម្លឹងមាសនោះយកមកអោយខ្លួនតាមវិធីណាទេ ។

-បានស្តាប់ក្រឡាបញ្ជីអានសារពើជាតិ និង សារណាតបរបស់ជនជាប់ចោទឈ្មោះយស់ សាឡាក់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលួង សុខា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះយស់ សាឡាត់ នាពេលសវនាការថា : ជនជាប់ចោទមានមុខរបរជាអ្នករត់តាក់ស៊ីពីភ្នំពេញទៅក្រុងព្រះសីហនុ ពេលដែលមាន PM មកជួលឡានក្នុងតំលៃ៦០$ ទៅខេត្តកោះកុងទៅយកប្អូនមកភ្នំពេញ បានន័យថា ឈ្មោះយស់ ឡាត់ ពុំមានទាក់ទិននឹងអំពើប្លន់នោះទេ ។ សូមអោយក្រុមប្រឹក្សាជំនុំជំរះបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង លើលែងចោទប្រកាន់លើឈ្មោះយស់ ឡាត់ ។

-បានស្តប់សេចក្តីសន្និដ្ឋានរបស់លោក ជ សម្បត្តិ មេធាវីការពារអោយជនជាប់ចោទឈ្មោះជន ផាន់ .ភុន សុភ័ក្រ និង ជ័យ ហួយ នាពេលសវនាការថា :

+ករណី : ជន ផាន់ និង ភុន សុភ័ក្រ បានសារភាពថា ខ្លួនពិតជាបានប្លន់មែន សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជំរះបន្ធូបន្ថយទោស ។

+ករណី : ជ័យ ហួយ នាងបានស្គាល់ឈ្មោះពៅ ប្រាប់ថា ទៅលេងកំពង់សោមពេលនោះប្ដីខ្លួនបានយក លុយ និង មាសមកអោយខ្លួនចំនួន៣០០$ ហើយខ្លួនមិនបានដឹងពីការប្លន់នោះទេ ។ ហេតុនេះសូមអោយក្រុមប្រឹក្សាជំនុំជំរះបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោល និង លើកលែងចោទប្រកាន់លើឈ្មោះជ័យ ហួយ ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ ថា : សូមរក្សាសេចក្ដីសន្និដ្ឋានរបស់ខ្លួនទុកជាបានការដដែល ពុំមានអ្វីបន្ថែម ទៀតទេ ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សារណាការពាររបស់ជនជាប់ចោទឈ្មោះ យស់ សាឡាត់ និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## *តុលាការកំពូល*

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់អ្នកស្រីទុន ទាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា ការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសារណា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ថា ទាំងតុលាការក្រុងព្រះសីហនុ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលបានសំរេចសេចក្ដីផ្ដន្ទាទោសជនជាប់ចោទ មានលក្ខណៈទាបពេក ដោយបន្ធូរបន្ថយទណ្ឌកម្ម និង ពុំមានវិធានការរឹបអូសទ្រព្យសម្បត្តិរបស់ពួកជនជាប់ចោទ ដើម្បីធានាសំណងអោយខ្លួនបានសមស្របតាមច្បាប់នៅឡើយទេ នោះជាការពុំត្រឹមត្រូវទេ ព្រោះថា :

+សាលាឧទ្ធរណ៍បានធ្វើការកែប្រែទណ្ឌកម្មលើជនជាប់ចោទពីទោសព្យួរមកដាក់ពន្ធនាគារវិញហើយ ឯប្រាក់សំណងក៏សាលាឧទ្ធរណ៍ បានសំរេចឱ្យជនជាប់ចោទទាំងអស់រួមគ្នាសងទៅជនរងគ្រោះ និង មានវិធានការសមស្របហើយដែរ ។ ម្យ៉ាងទៀតដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលស្គាល់ថា ខ្លួនបានទទួលសម្ភារៈតាមកំណត់ហេតុ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១ រួចហើយ ។

-យល់ឃើញថា ជនជាប់ចោទបានទទួលដីកាកោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ មានតែមេធាវីចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលាឧទ្ធរណ៍មានការខុសឆ្គងអំពីឈ្មោះរបស់ជនល្មើសឈ្មោះជន ផល ក្នុងចំណុច ២ "គ" តាមពិតជនល្មើសឈ្មោះជន ជាន់ ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ប៉ុន្តែកំហុសនេះជាកំហុសផ្នែកសំភារៈ តុលាការកំពូលគប្បីធ្វើការកែតំរូវ ។

-យល់ឃើញថា សាលាឧទ្ធរណ៍មានការខ្វះខាតក្នុងការសំរេចស្តីពីការដាក់គុកបង្ខំលើរូបកាយ ដើម្បីទារសំណងធនទណ្ឌ តុលាការកំពូលគប្បីសំរេចបន្ថែមតាមមាត្រា១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១០១"ង" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

*ហេតុដូច្នេះ*

*វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារអោយជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។*

១-ទទួលបណ្តឹងសាទុក្ខលេខ០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់អ្នកស្រីទុន ទាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១០១"ង" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ដោយកែតំរូវត្រង់ចំណុចទី២"គ" នៃសាលក្រមព្រហ្មទណ្ឌលេខ៣៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងព្រះសីហនុពីឈ្មោះផន ផល ដាក់ពន្ធនាគារកំណត់៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនមក ឈ្មោះផន ផាន់ វិញ ។

៣-ក្នុងករណីទណ្ឌិតទាំង៥នាក់ពុំមានប្រាក់សងត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារសំណងធនទណ្ឌតាមបញ្ញត្តិមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារសំណងធនទណ្ឌក្នុងរឿងព្រហ្មទណ្ឌ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ។